# សន្លឹកពតិមានសាធារណៈ

Ottawa County Health Depart

## ជំងឺប៉េស

**តើជំងឺប៉េស្តជាអ្វី ?**

ប៉េស្ត ជាជំងឺរបស់សត្វ និងមនុស្ស ដែលបណ្តាលមកពីបាក់តេរី ។ គេច្រើនឃើញវាកើតឡើងជាញឹកញាប់នៅលើសត្វកកេរ និងចៃរបស់វា ។ វាកំរមានណាស់នៅក្នុងសហរដ្ឋអាមេរិក ។

ជំងឺប៉េស្តមានបីប្រភេទសំខាន់ៗ : ប៉េស្តកូនកណ្តុរ ប៉េស្តផ្លូវ ដង្ហើម និងប៉េស្តក្នុងឈាម ។ ប្រភេទទាំងបីនេះបណ្តាលមក ពីបាក់តេរីដូចគ្នា ប៉ុន្តែរបៀបនៃការឆ្លង និងកន្លែងផ្សេងៗនៃ សរីរាង្គដែលឆ្លងមេរោគ គឺខុសៗគ្នា ។

**តើជំងឺប៉េស្តឆ្លងតាមរបៀបណា ?**

ប៉េស្តអាចឆ្លងតាមវិធីខាងក្រោមនេះ :

- ប៉េស្តកូនកណ្តុរ
  - o ការខាំដោយចៃដែលមានមេរោគ
  - o ប៉ះពាល់ជាមួយជាលិការបស់សត្វដែលផ្ទុកមេរោគ
- ប៉េស្តផ្លូវដង្ហើម
  - o ឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមតំណក់ទឹកផ្លូវដង្ហើម ( ក្អក កណ្តាស់ ទឹកមាត់)
  - o ធម្មតា វាឆ្លងក្នុងចំងាយ ៦ ហ្វ៊ុតពីអ្នកដែលផ្ទុកមេរោគ
- ប៉េស្តក្នុងឈាម
  - o កើតឡើងនៅពេលដែលមេរោគឆ្លងទៅដល់ក្នុងឈាម ។

គេក៏អាចប្រើមេរោគប៉េស្ត ធ្វើជាអាវុធជីវភេរវកម្ម ដោយធ្វើឱ្យមានការចំលងបាក់តេរីនេះតាមខ្យល់ ។

**តើប៉េស្តអាចមានរោគសញ្ញាអ្វីខ្លះ ?**

រោគសញ្ញាផ្សេងៗអាចមាន :

- ប៉េស្តកូនកណ្តុរ
  - o រងារស្រេវស្រាញ
  - o គ្រុនក្តៅ
  - o ឈឺក្បាល
  - o ឈឺចុកចាប់សាច់ដុំ
  - o ខ្សោយ
  - o ហើមរឹងកូនកណ្តុរ
- ប៉េស្តផ្លូវដង្ហើម
  - o ខ្សោយ
  - o ក្អក
  - o គ្រុនក្តៅ
  - o ដង្ហក់
- ប៉េស្តក្នុងឈាម
  - O មានជំងឺធ្ងន់ធ្ងរគ្រប់កន្លែង

បើគេមិនបានព្យាបាលប៉េស្តកូនកណ្តុរ ឬផ្លូវដង្ហើមទាន់ពេលទេ បាក់តេរីអាចឆ្លងទៅក្នុងចរន្តឈាមហើយបណ្តាលអោយកើតប៉េស្តក្នុងឈាម ។

**តើគេធ្វើរោគវិនិច្ឆ័យជំងឺប៉េស្តតាមរបៀបណា ?**

គេអាចធ្វើរោគវិនិច្ឆ័យប៉េស្ត តាមការពិនិត្យកំហាក ឈាម ខួរឆ្អឹងខ្នង ឬក្រពេញដែលឆ្លងរោគ ។

**តើគេព្យាបាលជំងឺប៉េស្តដូចម្តេច ?**

គេត្រូវចាប់ផ្តើមប្រើថ្នាំអង់ទីប៊ីយ៉ូទិកក្នុងរយៈពេល២៤ម៉ោងដំបូង ។ ប៉េស្តអាចបណ្តាលអោយស្លាប់បាន បើគេមិនបានព្យាបាលទាន់ពេល ។

**សំរាប់ពតិមានបន្ថែមស្តីអំពី ជំងឺប៉េស្ត សូមទាក់ទង :**

Ottawa County Health Department
www.miOttawa.org

Centers for Disease Control and Prevention
www.bt.cdc.gov/agent/plague/
ទូរស័ព្ទ : (888) 246-2675

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ : (616) 396-5266
ទូរសារ : (616) 393-5643
វ៉ិបសាយ : www.miOttawa.org